**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តស្វាយរៀង**

# របាយការណ៍
# ស្តីពី
# វឌ្ឍនភាព និងទិសដៅការងារបន្ត
# របស់ក្រុមប្រឹក្សាខេត្តស្វាយរៀង

ក្នុងសន្និសីទសារព័ត៌មាន ស្តីពីវឌ្ឍនភាពមូលដ្ឋានឃុំសង្កាត់ និងទិសដៅការងារបន្ត
នៅទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២២

**ជាបឋម ខ្ញុំព្រះករុណា-ខ្ញុំបាទ៖**

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ !
- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់ !
- សូមគោរព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ **ជាទីគោរពដ៏ខ្ពង់ខ្ពស់**!
- សូមគោរព **ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល **ជាទីគោរព**!
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មាន ដែលមានវត្តមាននៅក្នុងឱកាសនេះ **ជាទីមេត្រី**!
- បងប្អូនប្រជាពលរដ្ឋដែលកំពុងទស្សនាការផ្សាយផ្ទាល់ **ជាទីគោរពស្រលាញ់រាប់អាន**!

ថ្ងៃនេះ តាំងនាមក្រុមប្រឹក្សាខេត្តស្វាយរៀង និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ខ្ញុំសូមសម្តែងនូវសេចក្តីសោមនស្សរីករាយ ដែលត្រូវបានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល អញ្ជើញឱ្យចូលរួមជាវាគ្មិនកិត្តិយស ដើម្បីធ្វើបទបង្ហាញស្តីពី « **វឌ្ឍនភាពមូលដ្ឋានឃុំ-សង្កាត់ និងទិសដៅការងារបន្តរបស់ ខេត្តស្វាយរៀង** »។ សូមអរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូន

អ្នកសារព័ត៌មាន ទាំងអស់ដែលបានចូលរួមក្នុងសន្និសីទនេះ។ ចំពោះសមាសភាពគណៈប្រតិភូខេត្តស្វាយរៀង ដែលអញ្ជើញចូលរួមក្នុងអង្គសន្និសីទនេះរួមមាន៖

១/ **ឯកឧត្តម ជុំ ហាត** ប្រធានក្រុមប្រឹក្សាខេត្ត
២/ **លោកជំទាវ ប្រាក់ ពុទ្ធី** សមាជិកក្រុមប្រឹក្សាខេត្ត
៣/ **ឯកឧត្តម រាណា សុវណ្ណារិទ្ធិ** សមាជិកក្រុមប្រឹក្សាខេត្ត
៤/ **ឯកឧត្តម រស់ ផារិទ្ធ** អភិបាលរងខេត្ត
៥/ **លោកបណ្ឌិត ចិន សាធាន** នាយករដ្ឋបាលសាលាខេត្ត
៦/ **ឯកឧត្តមបណ្ឌិត កែវ រដ្ឋា** ប្រធានមន្ទីរសុខាភិបាលខេត្តនៃរដ្ឋបាលខេត្ត
៧/ **លោក កែវ ច័ន្ទលី** ប្រធានមន្ទីរព័ត៌មានខេត្ត
៨/ **លោក អ៊ូ សុខឿន** ប្រធានមន្ទីរការងារ បណ្តុះបណ្តាល និងវិជ្ជាជីវៈខេត្ត
៩/ **លោក សុខ សុទ្ធារ៉ុជ** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត
១០/ **លោក មាក ផវណ្ណារុន** ប្រធានមន្ទីរពាណិជ្ជកម្មខេត្ត
១១/ **លោក ឡុង សុខុម** ប្រធានមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្ត
១២/ **លោក សុខ សំអុល** ប្រធានសមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់
១៣/ **លោក សុទ្ធ គឹមច័ន្ទ** ប្រធានក្រុមប្រឹក្សាស្រុកស្វាយជ្រំ
១៤/ **លោក លឹម សៀងហេង** អភិបាលក្រុងបាវិត
១៥/ **លោក សុខ សំអន** មេឃុំស្វាយយា

ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋទាំងអស់ នៅក្នុងខេត្តស្វាយរៀងទាំងមូល ខ្ញុំសូមយកឱកាសនេះសម្តែងនូវការ ដឹងគុណយ៉ាងជ្រាវជ្រៅបំផុត ចំពោះការដឹកនាំប្រកបដោយ គតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលជា **«បិតាស្ថាបនិកសន្តិភាព»** និង **«សូមអរគុណសន្តិភាព»** ដែលធ្វើឱ្យប្រទេសជាតិ មានសុខសន្តិភាព ស្ថេរភាពនយោបាយ សុវត្ថិភាព សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិទាំងមូល ជាពិសេសខេត្តស្វាយរៀង មានការរីកចម្រើនលើគ្រប់វិស័យ។

អនុញ្ញាតឱ្យខ្ញុំព្រះករុណា-ខ្ញុំបាទ សូមគោរពរាយការណ៍ជូនសម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អំពីស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ សក្តានុពល សមិទ្ធផលនៃការអភិវឌ្ឍ ស្ថានភាពសេដ្ឋកិច្ច ការគ្រប់គ្រងដឹកនាំ និងវឌ្ឍនភាពការងារ របស់ក្រុមប្រឹក្សាខេត្តស្វាយរៀង សម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

## ១.សេចក្ដីផ្ដើម

ខេត្តស្វាយរៀង គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ ស្ថិតនៅប៉ែកអាគ្នេយ៍ មានចម្ងាយប្រមាណ១២៥គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ ដែលមានផ្លូវជាតិលេខ១ ឆ្លងកាត់ប្រវែង ៦៥គីឡូម៉ែត្រ មានព្រំប្រទល់៖

-ខាងជើង និងខាងលិចជាប់នឹងខេត្តព្រៃវែង

-ខាងកើត និងខាងត្បូង ជាប់នឹងខេត្តតៃនិញ និងខេត្តឡុងអាន ប្រទេសវៀតណាម

-មានផ្ទៃដីរួម ២.៩៦៦,៤០គីឡូម៉ែត្រក្រឡា

-ចែកចេញជា ២ក្រុង ៦ស្រុក ៦៨ឃុំ ១២សង្កាត់ ៦៩០ភូមិ

-មានប្រជាពលរដ្ឋសរុបចំនួន ៦៥៣.៧៦៦នាក់ ស្រី ៣៣៦.៦៣៨នាក់ ស្មើនឹង ១៥៦.០៥១គ្រួសារ ប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើង ចំនួន ៤២៥.៦៣៤នាក់ ។

- ប្រជាជនភាគច្រើនប្រកបមុខរបរកសិកម្មប្រមាណ ៥៨% ឧស្សាហកម្ម និងសេវាកម្ម ៤០% និងមុខរបរសិប្បកម្មប្រមាណ២%។

- មានតំបន់សេដ្ឋកិច្ចពិសេសចំនួន១២កន្លែង កំពុងដំណើរការ ៩កន្លែង សរុបទូទាំងខេត្ត មានក្រុមហ៊ុន រោងចក្រ សហគ្រាស គ្រឹះស្ថានឯកជន ធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សរុបចំនួន ២៤៧កន្លែង បង្កើតការងារធ្វើជូនប្រជាពលរដ្ឋប្រមាណ ៩៥.៤៧០នាក់ ក្នុងនោះកម្មករ កម្មការិនី នៅតាមរោងចក្រ សហគ្រាស មានចំនួន ៦ម៉ឺននាក់។

- មានផ្ទៃដីបង្កបង្កើនផលទាំងរដូវប្រាំង និងវស្សា មានចំនួន ១៧២.៣៩០ហិកតា ប្រមូលទិន្នផលបាន ៥០៤.៩៣០តោន គិតជាមធ្យមបាន ២.៨តោន ក្នុងមួយហិកតា ។

- មានច្រកទ្វារព្រំដែនចំនួន ៨កន្លែង រួមមាន ច្រកទ្វារព្រំដែនអន្តរជាតិ ២កន្លែង ច្រកទ្វារព្រំដែនទ្វេភាគី ២កន្លែង និងច្រកទ្វារតំបន់ ៤កន្លែង ដើម្បីសម្រួលការធ្វើដំណើរ និងការដឹកជញ្ជូនទំនិញពាណិជ្ជកម្មស្របតាមច្បាប់កំណត់។ ចំពោះការសម្រួលពាណិជ្ជកម្ម ដោះដូរផ្ទេរទំនិញ រវាងភាគីទាំងពីរ គឺនៅមានសកម្មភាពដំណើរការជាធម្មតានៅតាមច្រកទ្វារព្រំដែនអន្តរជាតិទាំងពីរ និងច្រកទ្វារព្រំដែនទ្វេភាគីបុសមន ដោយអនុវត្តត្រឹមត្រូវតាមការណែនាំ របស់រាជរដ្ឋាភិបាលកម្ពុជា និងវិធានការសុខាភិបាល ។

អនុវត្តតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានា តម្រូវឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលកើតឡើងដោយការបោះឆ្នោតអសកលត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់ តាមរយៈការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដោយឡែកក្រុមប្រឹក្សាខេត្តស្វាយរៀង អាណត្តិទី៣ បានប្រកាសទទួលស្គាល់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៩/៧៦៣ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩ មានសមាសភាព

ចំនួន២៣រូប ដែលដឹកនាំដោយឯកឧត្តម **ជុំ ហាត** ប្រធានក្រុមប្រឹក្សាខេត្ត និងឯកឧត្តម លោកជំទាវ សមាជិក សមាជិកាក្រុមប្រឹក្សាចំនួន ២២រូប ក្នុងនោះស្ត្រីចំនួន ០៧រូប។ ចាប់តាំងពីថ្ងៃចូលកាន់តំណែង រហូតមកដល់បច្ចុប្បន្ននេះ ក្រុមប្រឹក្សាខេត្តស្វាយរៀង បានអនុវត្តតួនាទីភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន តាមរយៈអង្គប្រជុំក្នុងការចាត់ចែងកិច្ចការចាំបាច់ នានា ដើម្បីធានាធ្វើឱ្យបាន សម្រេចនូវគោលបំណងក្នុងការបំពេញមុខងារ ភារកិច្ច ដែលរាជរដ្ឋាភិបាលបានប្រគល់ និងបានធ្វើប្រតិភូកម្មជូនតាមច្បាប់គតិយុត្ត ក្នុងនាមក្រុមប្រឹក្សាដែលមានតួនាទីជាចម្បង ក្នុងការធានាលើការផ្តល់សេវា និងការអភិវឌ្ឍជូនប្រជាពលរដ្ឋ ប្រកបដោយគុណភាព ប្រសិទ្ធភាព ដោយឈរលើគោលការណ៍អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដែលមានគណនេយ្យភាពជាមួយរាជរដ្ឋាភិបាល និងជាមួយប្រជាពលរដ្ឋ។

## ២. វឌ្ឍនភាពរបស់ក្រុមប្រឹក្សាខេត្តស្វាយរៀង

អនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្រោមការដឹកនាំប្រកប ដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងនាមក្រុមប្រឹក្សាខេត្ត បានខិតខំយកចិត្តទុកដាក់ បំពេញតួនាទីភារកិច្ចរបស់ខ្លួនដោយធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ តាមរយៈការដាក់ចេញនូវ សេចក្តីសម្រេច ដីកា វិធានការ គោលការណ៍ គោលនយោបាយ និងសេចក្តីសម្រេចខាងប្រតិបត្តិតាមរយៈកិច្ចប្រជុំក្រុមប្រឹក្សា រួមមាន ផែនការអភិវឌ្ឍ ៥ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ថវិកាប្រចាំឆ្នាំ និងការដោះស្រាយតម្រូវការដាក់លាក់បន្ទាន់ណាមួយ ដោយធានាថាសេចក្តីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការ តាមដាន និងវាយតម្លៃជាប្រចាំ ដែលមានគណៈអភិបាលខេត្តដឹកនាំដោយឯកឧត្តម **ម៉ែន វិបុល** ជាអ្នកចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សា។ បានអនុវត្តការងារស្របតាមតួនាទី ភារកិច្ចរបស់ខ្លួន សំដៅជំរុញ កសាង និងអភិវឌ្ឍខេត្ត ធ្វើឱ្យខេត្តស្វាយរៀងមានការរីកចម្រើនលើគ្រប់វិស័យ ជាពិសេសលើវិស័យឧស្សាហកម្ម។ ការអនុវត្តនូវមុខងារជាកាតព្វកិច្ច ដែលត្រូវបានផ្ទេរមកឱ្យក្រុមប្រឹក្សាខេត្ត ជាលក្ខណៈប្រគល់ ឬធ្វើប្រតិភូកម្ម ដែលត្រូវអនុវត្តដោយខានមិនបាន រីឯមុខងារ ជាជម្រើសដែលក្រុមប្រឹក្សាអាចជ្រើសរើសយកមកអនុវត្ត អាស្រ័យលើតម្រូវការជាក់ស្តែង ធ្វើឡើងដើម្បីធានាឱ្យបាននូវស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ទូទាំងខេត្តមានលក្ខណៈល្អប្រសើរ និងធានាដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ប្រកបដោយភាពសុខដុមរមនា។ ក្នុងនោះកាតព្វកិច្ចដែលក្រុមប្រឹក្សាខេត្តត្រូវរៀបចំមុនគេ គឺការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ដែលជាត្រីវិស័យ ក្នុងការដឹកនាំ និងអភិវឌ្ឍន៍ខេត្ត ក្នុងមួយអាណត្តិ និងមានគណៈកម្មាធិការជំនាញ៣សំខាន់ៗ ដែលជាសេនាធិការរបស់ក្រុមប្រឹក្សាខេត្ត ទី១៖គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ជាសេនាធិការត្រួតពិនិត្យទៅលើតម្រូវការជាអទិភាពសំខាន់ៗក្នុងការ រៀបចំផែនការ

និងគម្រោងអភិវឌ្ឍន៍ ដែលមានវិសាលភាពគ្រប់ដណ្ដប់ លើរដ្ឋបាលខេត្តទាំងមូល។ ទី២៖ គណៈកម្មាធិការលទ្ធកម្ម ជាសេនាធិការ ក្នុងការត្រួតពិនិត្យទៅលើគម្រោងអភិវឌ្ឍន៍នានា និងធានាបាននូវតម្លាភាព គុណភាព និងប្រសិទ្ធភាព ស្របតាមច្បាប់បទដ្ឋានគតិយុត្ត ជាធរមាន។ ទី៣៖ គណៈកម្មាធិការ ពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ជាសេនាធិការលើកិច្ចការ ផ្សារភ្ជាប់ជាមួយស្ត្រី ចាស់ជរា និងកុមារ ក្នុងការអភិវឌ្ឍជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងមានការិយាល័យប្រជាពលរដ្ឋ ជាសេនាធិការលើការទទួលនូវសំណូមពរ ធ្វើការដោះស្រាយទំនាស់ និងវិវាទក្រៅប្រព័ន្ធតុលាការ ជូនប្រជាពលរដ្ឋ ។

-បានអនុវត្តយ៉ាងទៀងទាត់ប្រចាំខែ តាមប្រតិទិន និងតាមបទបញ្ជាផ្ទៃក្នុង នៅក្នុងកិច្ចប្រជុំសាមញ្ញរបស់ខ្លួន ដោយក្នុងមួយឆ្នាំយ៉ាងតិច ១២លើក ហើយចន្លោះពីមួយលើកទៅមួយលើកមិនត្រូវធ្វើមុនរយៈពេល ២៥ថ្ងៃ នឹងមិនឱ្យលើសពីរយៈពេល៣៥ថ្ងៃ និងមានកិច្ចប្រជុំវិសាមញ្ញក្នុងការចាំបាច់ របស់រដ្ឋបាលខេត្ត។

-បានប្រជុំ អនុម័តរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងលើកទិសដៅការងារបន្តទៅលើវឌ្ឍនភាពរបស់ខេត្តស្វាយរៀងជាប្រចាំ តាមរយៈកិច្ចប្រជុំដើម្បីធ្វើការតាមដាននូវវឌ្ឍនភាព ជាពិសេសបំពេញបន្ថែម ឬកែលំអ លើបញ្ហាដែលនៅសេសសល់ ដែលធ្វើឱ្យវឌ្ឍនភាពរបស់ខេត្ត ពីមួយខែទៅមួយខែកាន់តែប្រសើរឡើង និងរីកចម្រើនជាលំដាប់ ដែលមានមន្ទីរ អង្គភាព ជំនាញ ជាសេនាធិការ

-បានពិនិត្យ និងអនុម័តផែនការអភិវឌ្ឍខេត្តរយៈពេល៥ឆ្នាំ ដែលជាត្រីវិស័យ របស់ក្រុមប្រឹក្សាក្នុងមួយអាណត្តិ

-បានពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្ត ដែលជាយន្តការតាមដានជាប្រចាំ នូវការអនុវត្តគម្រោងអភិវឌ្ឍន៍ប្រចាំឆ្នាំ ដែលជាផែនទីចង្អុលផ្លូវ និងជាត្រីវិស័យក្នុងការវាស់ ការកែលំអ ឬបំពេញបន្ថែម ធ្វើយ៉ាងណាឱ្យសម្រេចបានទៅតាមផែនការអភិវឌ្ឍន ៥ឆ្នាំ ដែលជាផែនការយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សា

-តាមរយៈវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ក្រុមប្រឹក្សាខេត្ត ឆ្នាំ២០២០ បានទទួលសំណើ សំណូមពរចំនួន ៨៥ បានធ្វើការឆ្លើយតប និងដោះស្រាយដាក់ចូលក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល របស់ខេត្ត និងមន្ទីរ អង្គភាព និងតាមរយៈក្រសួង ស្ថាប័ន វិស័យឯកជន និងដៃគូរអភិវឌ្ឍន៍

-ក្នុងឆ្នាំ២០២១ តាមរយៈការិយាល័យប្រជាពលរដ្ឋ បានទទួលពាក្យបណ្ដឹងចំនួន **៧១** បណ្ដឹង បានដោះស្រាយសម្របសម្រួលទំនាស់ ចំនួន **៦៤**បណ្ដឹង រីឯបណ្ដឹងចំនួន **០៧ករណី** បានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ ព្រោះជាបណ្ដឹងក្រៅដែនសមត្ថកិច្ច។

-រដ្ឋបាលខេត្តមានអង្គភាពច្រកចេញចូលតែមួយ ដែលជាអង្គភាពបម្រើសេវាប្រជាពលរដ្ឋ ជាកន្លែងប្រមូលផ្តុំសេវានៅកន្លែងតែមួយតាមនីតិវិធីសាមញ្ញ បម្រើសេវាកាន់តែលឿន រហ័ស មានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាពនិងកាន់តែផ្តល់ភាពងាយស្រួល ។ ក្នុងឆ្នាំ២០២១ ការផ្តល់សេវារបស់អង្គភាពច្រកចេញចូលតែមួយខេត្ត ទទួលបានសេវាសរុបចំនួន ២៧.៩៨១ សេវា ដែលសរុបជាទឹកប្រាក់ចំនួន ២.៤៦១.៥៥០.៦០២រៀល(ពីរប៊ីលាន បួនរយហុកសិប មួយលាន ប្រាំរយហាសិបពាន់ ប្រាំមួយរយពីររៀល) លើវិស័យជំនាញចំនួន១២ បន្ថែមលើ សេវារដ្ឋបាល ។ ក្រៅពីនេះរដ្ឋបាលក្រុង ស្រុកទាំង៨មានក្រុង ស្រុក ចំនួន៤ដែលមានអគារ ការិយាល័យច្រកចេញចូលតែមួយ រួមមាន៖ ក្រុងស្វាយរៀង ក្រុងបាវិត ស្រុកស្វាយជ្រំ និងស្រុក រមាសហែក

- ក្រុមប្រឹក្សាខេត្តបានចូលរួមកិច្ចប្រជុំជាមួយក្រុមប្រឹក្សាប្រភេទផ្សេងគ្នា ក្នុងគោលបំណង ពិគ្រោះយោបល់ និងគាំទ្រលើបច្ចេកទេស ក្នុងការអនុវត្តនូវមុខងារដែលបានប្រតិភូកម្មដល់ ក្រុង ស្រុក ឃុំ សង្កាត់

- ចំពោះការអនុវត្តថវិកាគុណប្រយោជន៍ខេត្ត ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ នៅក្នុងឆ្នាំ២០២១ កន្លងទៅនេះ រដ្ឋបាលខេត្ត ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាខេត្ត និង ការអនុវត្តផ្ទាល់របស់គណៈអភិបាលខេត្ត សម្រេចបានលទ្ធផលដូចខាងក្រោម ៖

- បានសាងសង់អគាររដ្ឋបាលឃុំ សង្កាត់ចំនួន៧៦ ត្រៀមសាងសង់ក្នុងឆ្នាំ២០២២ មានចំនួន២(សាលាឃុំគ្រោលគោ និងឃុំពោធិតាហោ) នៅសល់ចំនួន ២ ដែល មិនអាចសាងសង់បាន (សង្កាត់ស្វាយរៀង និងសង្កាត់ច្រកម្ទេស) ដោយសារដី សម្រាប់សាងសង់តូចចង្អៀត។ ក្នុងនោះការគាំទ្រដោយក្រសួងមហាផ្ទៃ ៧ឃុំ-សង្កាត់ រដ្ឋបាលខេត្ត ៣៤ឃុំ-សង្កាត់ គម្រោងADB ២៧ ឃុំ- សង្កាត់ និងសប្បុរសជន ៨ ឃុំ-សង្កាត់
- បានជួសជុលផ្លូវបេតុង ផ្លូវអ៊ុតកៅស៊ូបេទីមAC ចំនួន ០៤ខ្សែ មានប្រវែង ៧.០៤០ ម៉ែត្រ
- បានជួសជុលលូរំដោះទឹក ប្រវែង ៩៦៤ម៉ែត្រ
- បានកែលម្អសោភ័ណ្ឌភាពក្នុងក្រុងស្វាយរៀង រួមមាន៖ កែលម្អសោភ័ណ្ឌភាព សួនច្បារ ស្ដាបនាផ្លូវនៅបរិវេណសួនច្បារ និងបានបំពាក់អំពូលភ្លើង LED តាមដង ផ្លូវ ដើម្បីបង្កើនសោភ័ណ្ឌភាព ក្នុងទាក់ទាញប្រជាពលរដ្ឋចូលទស្សនាកម្សាន្ត។
- បានកសាងច្រាំងទន្លេវៃគោ រៀបការ៉ូឡា និងសួនក្នុងក្រុងស្វាយរៀង ដើម្បីផ្តល់ជា ទីតាំងដល់បងប្អូនប្រជាពលរដ្ឋហាត់ប្រាណ និងជាកន្លែងទេសចរណ៍កំសាន្ត

- អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ពិសេសអនុសាសន៍ ដ៏ខ្ពង់ខ្ពស់ របស់សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងផ្តល់ដំបូន្មានថាយើង មិនត្រូវទុកឱ្យប្រជាពលរដ្ឋណាម្នាក់មានគ្រោះថ្នាក់ ឬស្លាប់ដោយសារយើងមិនបានយកចិត្តទុក ដាក់ជួយដោះស្រាយនោះទេ រដ្ឋបាលខេត្ត ដោយមានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ សម្បទា និងមន្ទីរផែនការខេត្ត ជាសេនាធិការ បានយកចិត្តទុកដាក់ អនុវត្តកម្មវិធីឧបត្ថម្ភសាច់

ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ គិតមកដល់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ បានផ្តល់សរុបចំនួន **១៨.៤៤៧**នាក់ ស្មើនឹងថវិកាសរុប **១.០៦៥.២៤០.០០០រៀល (មួយពាន់លាន ហុកសិបប្រាំលាន ពីររយសែសិបពាន់រៀល)** ក្នុងនោះស្ត្រីសម្រាលកូន និងមានផ្ទៃពោះ សរុបចំនួន ៦.១១៥នាក់ និងកុមារអាយុក្រោមពីរឆ្នាំចំនួន ១២.៣៣២នាក់។

-បានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលជំងឺកូវីដ-១៩ គិតចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដល់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ មានចំនួន៣២.៦៩៩គ្រួសារ ស្មើនឹងទឹកប្រាក់ ៦៨.៤០៣.០៤៨.០០០រៀល(ហុកសិបប្រាំបីពាន់លាន បួនរយបីលាន សែសិបប្រាំបីពាន់រៀល)។

## ការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្នុងក្របខណ្ឌនៃការលើកកម្ពស់អភិបាលកិច្ច រដ្ឋបាលខេត្តស្វាយរៀង បានយកចិត្តទុកដាក់ចូលរួមអនុវត្តកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល រួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលជាកំណែទម្រង់ស្នូល នៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ជាពិសេសកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ តាមរយៈការអនុវត្តកម្មវិធីកំណែទម្រង់នេះ រដ្ឋបាលថ្នាក់ក្រោមជាតិ បានបំពេញតួនាទី និងការទទួលខុសត្រូវយ៉ាងសំខាន់ ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនានាឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងដោះស្រាយបញ្ហាប្រឈមជាអាទិភាពនានា នៅតាមមូលដ្ឋាន ដែលប្រការនេះបានចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់ការលើកកម្ពស់ជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ផ្អែកលើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រាជរដ្ឋាភិបាល បានរៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រយៈពេល ១០ឆ្នាំ (២០១០-២០២០) កម្មវិធីជាតិនេះ ជាផែនទីបង្ហាញផ្លូវ សម្រាប់ការអនុវត្តច្បាប់រៀបចំអង្គការ ជាជំហានៗ សំដៅឆ្ពោះទៅរកការឯកភាព ស្រុះស្រួលគ្នា និងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ សំដៅលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍសេដ្ឋកិច្ច ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ដោយអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ ១៨២ និង១៨៤ អនក្រ.បក ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក របស់រាជរដ្ឋាភិបាល រដ្ឋបាលខេត្តស្វាយរៀង ក្រោមការដឹកនាំរបស់ **ក្រុមប្រឹក្សាខេត្ត** និង **គណៈអភិបាលខេត្ត** បានយកចិត្តទុកដាក់ រៀបចំធ្វើសមាហរណកម្មបុគ្គលិក ដែលកំពុងបម្រើការងារនៅតាមការិយាល័យអង្គភាព នៃរដ្ឋបាលក្រុង ស្រុក និងនៅតាមការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ចូលទៅក្នុងរចនាសម្ព័ន្ធថ្មី នៃរដ្ឋបាលក្រុង ស្រុក។

## ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ១៩

-ដោយអនុវត្តតាមវិធានការណែនាំសុវត្ថិភាពរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល រដ្ឋបាលខេត្ត ក្រុង ស្រុក និងទទួលបានការគាំទ្រពីក្រុមការងាររដ្ឋាភិបាល បានបើកយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ប្រកបដោយជោគជ័យ ដោយ

អនុវត្តតាមវិធានការ ៣កុំ ៣ការពារ និងបានចាក់វ៉ាក់សាំងជូនដល់មន្ត្រីរាជការ កងកម្លាំងទាំងបី និងប្រជាពលរដ្ឋក្នុងខេត្តគិតត្រឹមថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ សរុបទាំងអស់ចំនួន**៤២១.៥៦០នាក់ ស្មើ៩១% អ្នកមិនទាន់បានចាក់វ៉ាក់សាំងមានចំនួន ៤២.៧០៣នាក់ ស្មើ៩% ចាក់ដូសជំរុញ បានចំនួន ១៦៦.៣៧៦នាក់ ស្មើ៣៨%** ។ គិតត្រឹម ខែមករា ឆ្នាំ២០២២ ករណីវិជ្ជមានជំងឺកូវីដ-១៩ ក្នុងខេត្តសរុបទាំងអស់ចំនួន**៦.៣៣០នាក់** ស្រី**៣.៤៤១នាក់** ជាសះស្បើយ **៦.០៨១នាក់** ស្រី **៣.២៩៥នាក់** ក្នុងនោះស្លាប់ **១៧៣នាក់** ស្រី**១០២នាក់** ។

- ក្រុមប្រឹក្សាខេត្ត បានចូលរួមជាមួយគណៈអភិបាលក្នុងការប្រយុទ្ធប្រឆាំងការរីករាលដាល នៃជំងឺកូវីដ១៩ មានដូចជា៖

  - បានចុះអប់រំផ្សព្វផ្សាយអំពីវិធានការការពារ និងបង្ការការឆ្លងជំងឺកូវីដ-១៩
  - ចូលរួមក្នុងការបរិច្ចាកថវិកាជូនរាជរដ្ឋាភិបាល ក្នុងការទិញវ៉ាក់សាំង កូវីដ-១៩

- តាមរយៈការយកចិត្តទុកដាក់ពីក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត បានអនុវត្តសកម្មភាពអប់រំលើកកម្ពស់អនាម័យជនបទ ប្រជាពលរដ្ឋបានយល់ដឹងពីសារៈសំខាន់នៃការទម្លាប់អនាម័យល្អប្រចាំថ្ងៃ តាមរយៈការប្រតិបត្តិអនាម័យល្អ៣យ៉ាងគឺ បន្ទោរបង់ក្នុងបង្គន់ ហូបទឹកស្អាត និងលាងដៃជាមួយសាប៊ូ ជាពិសេសចូលរួមអនុវត្តវិធានការ ៣កុំ និង៣ការពារ របស់រាជរដ្ឋាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ជាហេតុធ្វើឱ្យស្ថានភាពអនាម័យទូទាំងខេត្តស្វាយរៀង រីកចម្រើនបានល្អប្រសើរយ៉ាងឆាប់រហ័ស។ មកដល់បច្ចុប្បន្ននេះអត្រាគ្រប់ដណ្តប់អនាម័យ **ការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល(ODF)** ទូទាំងខេត្តសម្រេចបាន១០០% ។ កត្តាដែលនាំឱ្យការធ្វើ **ការបញ្ឈប់បន្ទោរបង់ពាសវាលពាសកាល (**ODF) ទទួលបានជោគជ័យ ១០០% គឺមានកត្តាសំខាន់ៗចំនួន៥៖ **១.ការសម្របសម្រួល :** ដោយមានការសហការល្អប្រសើររបស់ក្រុមការងារអនាម័យជនបទថ្នាក់ខេត្ត ក្រុង ស្រុក ក្នុងការផ្សព្វផ្សាយតាមខ្នងផ្ទះ។ **២.ផែនការយុទ្ធសាស្រ្ត :** ការធ្វើបច្ចុប្បន្នភាពផែនការជាប្រចាំ និងការលើកទឹកចិត្ត(ថវិកា និងសម្ភារៈ)ដល់អ្នកអនុវត្តផ្ទាល់ជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ។ **៣.ពិនិត្យ និងតាម**ដាន : ការធ្វើបច្ចុប្បន្នភាពសៀវភៅទិន្នន័យអនាម័យ ការគូសលើផែនទីអនាម័យភូមិ(កំណើនបង្គន់ និងកន្លែងលាងសម្អាតដៃថ្មីៗ) និងការរកដំណោះស្រាយខ្នងផ្ទះដែលគ្មានបង្គន់។ **៤.ការផ្តល់សេវាកម្ម :** ការជំរុញ និងលើកទឹកចិត្តឱ្យសាងសង់ និងការស្វែងរកការគាំទ្រពីអង្គការដៃគូក្នុងការឧបត្ថម្ភធន ។ **៥.ការពង្រឹងសមត្ថភាព** : ការពង្រឹងសមត្ថភាពដល់មន្ត្រីថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងការចុះ ធ្វើការអប់រំ ផ្សព្វផ្សាយ និងការកត់ត្រាសៀវភៅទិន្នន័យអនាម័យ និងការគូសផែនទីអនាម័យភូមិ។

**៣.យន្តការនៃការអនុវត្តការងារ របស់ក្រុមប្រឹក្សាខេត្ត ក្នុងការជំរុញ និងគាំទ្រ ដើម្បីប្រសិទ្ធភាពការងាររបស់មូលដ្ឋាន (ឃុំ-សង្កាត់)**

ដើម្បីឱ្យការអនុវត្តការងារឱ្យមានគុណភាព ប្រសិទ្ធភាព បរិយាប័ន្ន ក្នុងការគាំទ្រមូលដ្ឋាន ឃុំ សង្កាត់ រដ្ឋបាលខេត្តបានអនុវត្តតាមអនុក្រឹត្យលេខ ២១៦ អនក្រ បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខេត្តបានធ្វើការគាំទ្រ ៥ចំណុចទៅដល់ក្រុង ស្រុក ឃុំ សង្កាត់ ដូចខាងក្រោម៖

១. ការគាំទ្រលើការពិគ្រោះយោបល់ : ចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ពិគ្រោះយោបល់ ក្នុងគោលបំណងឆ្លើយតបនូវតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស

២. វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព : បណ្តុះបណ្តាលតម្រង់ទិស ស្តីពីការគ្រប់គ្រងរដ្ឋបាលក្រុង-ស្រុក, បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងបុគ្គលិក និងកិច្ចការរដ្ឋបាលខេត្ត ក្រុង-ស្រុក ដើម្បីឆ្លើយតបទៅនឹងមុខងារដែលបានប្រតិភូកម្ម។

៣. ការកសាងផែនការកម្មវិធីវិនិយោគ : គាំទ្រដល់ក្រុមប្រឹក្សាក្រុង-ស្រុក ឃុំ-សង្កាត់ ក្នុងការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍ ៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

៤. ការគាំទ្រលក្ខណៈបច្ចេកទេស : ការរៀបចំវេទិកាពិគ្រោះយោបល់ ស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ការរៀបចំ ក្នុងការសិក្សាគម្រោង រៀបចំប្លង់ការប៉ាន់ស្មានតម្លៃ និងការរៀបចំគម្រោង គាំទ្រលក្ខណៈបច្ចេកទេស ក្នុងកិច្ចប្រជុំគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ នៅតាមក្រុង-ស្រុក ឃុំ-សង្កាត់។

៥. ការចុះសួរសុខទុក្ខ : តាមរយៈគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារខេត្ត ចុះសួរសុខទុក្ខ ស្ត្រីក្រីក្រ កុមារកំព្រា និងជនងាយរងគ្រោះ នៅថ្នាក់ឃុំ សង្កាត់ ដែលបានយកចិត្តទុកដាក់ និងមិនឱ្យស្ត្រី និងកុមារណាម្នាក់មានភាពឯកោ។

**៤. ទិសដៅការងាររបស់ក្រុមប្រឹក្សាខេត្ត**

-បន្តកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ដោយអនុវត្តទៅតាមប្រតិទិននៃកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្តក្នុងករណីចាំបាច់

-បន្តចូលរួមកិច្ចប្រជុំសាមញ្ញ ប្រចាំខែ ជាមួយក្រុមប្រឹក្សាប្រភេទផ្សេងគ្នា ដើម្បីពិគ្រោះយោបល់ និងគាំទ្រក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាក្រុង-ស្រុក ឃុំ-សង្កាត់ ដែលបានធ្វើប្រតិភូកម្ម។

-បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ របស់ក្រុមប្រឹក្សាខេត្ត ជាមួយប្រជាពលរដ្ឋតាមបណ្តាក្រុង-ស្រុក ដើម្បីប្រមូលនូវបញ្ហាប្រឈម និងសំណូមពររបស់ប្រជាពលរដ្ឋ

-បន្តសហការជាមួយសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ដើម្បីរួមចំណែកការពារផលប្រយោជន៍ និងចូលរួមវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពបន្ថែម ដល់ក្រុមប្រឹក្សាក្នុងការអនុវត្តការងារ

-តាមដាន ត្រួតពិនិត្យ នូវការអនុវត្តផែនការ ឱ្យសម្រេចបានលទ្ធផលល្អ តាមរយៈផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ស្របតាមយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាខេត្ត ក្នុងអាណត្តិទី៣

-បន្តការគាំទ្រ តាមដាន ជំរុញនិងដាក់ចេញជាយន្តការលើការអនុវត្តមុខងារ ដែលបានប្រតិភូកម្មពីក្រសួងស្ថាប័នថ្នាក់ជាតិ ទៅថ្នាក់ក្រុង-ស្រុក និង ឃុំ-សង្កាត់ ព្រមទាំងការបើកវគ្គបណ្តុះបណ្តាលការពង្រឹងសមត្ថភាពជាបន្តបន្ទាប់

-បន្តជំរុញយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈការិយាល័យប្រជាពលរដ្ឋ និងការប្រឹក្សាផ្តល់យោបល់ពីមេធាវីប្រចាំរដ្ឋបាលខេត្ត

-បន្តដាក់ចេញនូវវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ កុំឱ្យមានការរីករាលដាលដល់ប្រជាពលរដ្ឋនៅតាមសហគមន៍ស្របតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ការអនុវត្តវិធានការ ៣កុំ និង៣ការពារ។

-បន្តជំរុញការគាំទ្រ និងតាមដានត្រួតពិនិត្យ ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោមពីរឆ្នាំ នៃគ្រួសារក្រីក្រ ព្រមទាំងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលនៃជំងឺកូវីដ-១៩ ឱ្យបានទាន់ពេលវេលា និងត្រឹមត្រូវតាមគោលការណ៍របស់រាជរដ្ឋាភិបាល និងចំគោលដៅ។

ជាទីបញ្ចប់ក្នុងនាមក្រុមប្រឹក្សាខេត្តស្វាយរៀង ខ្ញុំបាទសូមគោរពជូនពរៈ

- សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាព អ្នកនាំពាក្យរាជរដ្ឋាភិបាល
- គណៈប្រតិភូខេត្តស្វាយរៀង បងប្អូនអ្នកសារព័ត៌មាន និងបងប្អូនប្រជាពលរដ្ឋដែលកំពុង ទស្សនា សូមជួបប្រទះនូវពុទ្ធពរ ទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

សូមអរគុណ!